សិល្បៈខ្មែរអមតៈ

**ការពិពណ៌នាការងារ ៖**
**ជំនួយការទូទៅ មណ្ឌលសិល្បៈនិងវប្បធម៌**

## ផ្នែក កៈ ពត៌មានទូទៅ

| | |
|---|---|
| មុខងារៈ | ជំនួយការទូទៅ មណ្ឌលសិល្បៈនិងវប្បធម៌ |
| ទីតាំងៈ | មណ្ឌលសិល្បៈនិងវប្បធម៌<br>នៅក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិ, រាជធានីភ្នំពេញ |
| ទទួលខុសត្រូវចំពោះៈ | អ្នកសម្របសម្រួល កម្មវិធីអប់រំសិល្បៈនិងវប្បធម៌ |

## ផ្នែក ខៈ អំពីសិល្បៈខ្មែរអមតៈ

យើងជឿជាក់ថា សង្គមមួយអាចរីកចម្រើនពេញលេញទៅបាន ដោយមានការចូលរួមពីសិល្បៈ ។ យើងមានទស្សនវិស័យថា សិល្បៈនិងវប្បធម៌ មានសារៈសំខាន់ដែលមិនអាចខ្វះបានសម្រាប់អនាគតដ៏រុងរឿងរបស់កម្ពុជា ។ បេសកកម្ម នៃអង្គការសិល្បៈខ្មែរអមតៈ គឺដើរតួជាកត្តាជំរុញ នៅក្នុងវិស័យសិល្បៈដ៏រស់រវើក ដែលជួយញ៉ាំងទឹកចិត្តអ្នកជំនាន់ថ្មី ។

**យុទ្ធសាស្ត្រសម្រាប់គោលដៅរបស់យើងក្នុងអំឡុងឆ្នាំ ២០១៧-២០២១ គឺ ៖**

- ផ្តល់លទ្ធភាពដល់សិល្បករ និងអ្នកដឹកនាំផ្នែកវប្បធម៌ តាមរយៈ ការបណ្តុះបណ្តាល, ការផ្តល់មូលនិធិនិងធនធាន។
- បញ្ជ្រាបសិល្បៈនិងវប្បធម៌ទៅក្នុងបទពិសោធន៍ជីវិតរបស់មនុស្សវ័យក្មេង ។
- ពង្រីកទីផ្សារ និងទស្សនិកជន សម្រាប់សិល្បៈទស្សនីយភាព នៅកម្ពុជា ។
- សម្របសម្រួលឲ្យមានទំនាក់ទំនង និងសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព នៅតាម បណ្តាសហគមន៍សិល្បៈនៅកម្ពុជា និងតំបន់អាស៊ី ។

**គោលបំណងបន្ថរបស់យើងគឺ ៖**

- ដឹកនាំ គំនិតផ្តួចផ្តើមផ្នែកសិល្បៈសំខាន់ៗ ដែលគាំទ្រអភិវឌ្ឍវិស័យសិល្បៈនៅកម្ពុជា ។
- សម្របសម្រួល និងលើកស្ទួយការផ្លាស់ប្តូរវប្បធម៌គ្នាទៅវិញទៅមក ក្នុងតំបន់ និងក្រៅតំបន់ ។
- ជួយគាំទ្រនិរន្តរភាព នៃស្នាដៃមតិកសិល្បៈខ្មែរ ។

## ផ្នែក គៈ ទិដ្ឋភាពទូទៅនៃមុខតំណែង

អង្គការសិល្បៈខ្មែរអមតៈ កំពុងដំណើរការ គម្រោងសាកល្បង៥ឆ្នាំ ក្នុងការពង្រឹងសកម្មភាពអប់រំសិល្បៈនិងវប្បធម៌ តាមគ្រឹះស្ថានអប់រំរដ្ឋនៅកម្ពុជា ដោយមានកិច្ចសហការជាមួយ ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ព្រមទាំងអង្គការយូណេស្កូកម្ពុជា ។

មណ្ឌលសិល្បៈនិងវប្បធម៌ នៅក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិ មានគោលបំណងប្រែក្លាយជាមណ្ឌលគំរូមួយក្នុងការបង្កើតឲ្យមានសកម្មភាពអប់រំសិល្បៈប្រកបដោយភាពច្នៃប្រឌិត ជំរុញការចូលរួមពីសិស្សានុសិស្សនៃសាលានានាជិតខាង និងសហគមន៍ជុំ

វិញ ដោយផ្តល់លទ្ធភាពឲ្យចូលរួមក្នុងសកម្មភាពសិល្បៈផ្សេងៗ ដើម្បីបង្កើនចំណេះដឹង បទពិសោធន៍ លើកស្ទួយ និងផ្តល់គុណតម្លៃ លើវិស័យសិល្បៈវប្បធម៌ជាតិ ។

ជំនួយការទូទៅមណ្ឌលសិល្បៈនិងវប្បធម៌ មានតួនាទីសំខាន់ជួយរៀបចំសណ្តាប់ធ្នាប់ ធានាសុវត្ថិភាព និងអនាម័យ ក្នុងបរិវេណជុំវិញ ។ លើសពីនេះ ត្រូវជួយមើលខុសត្រូវក្លឹបសិល្បៈ (ថ្ងៃសៅរ៍-អាទិត្យ) និងជួយកិច្ចការទូទៅ ដូចជាការទទួល បដិសណ្ឋារកិច្ចភ្ញៀវ (សិស្សានុសិស្ស, សិល្បករ-ការិនី, លោកគ្រូ-អ្នកគ្រូ) ដែលមកប្រាស្រ័យទាក់ទងក្នុងមណ្ឌល, ការងារការិយាល័យទូទៅ និងជាជំនួយការផ្សេងៗពេលមានសកម្មភាពសិល្បៈជាដើម ។

## ផ្នែក ឃ៖ ទំនួលខុសត្រូវ

- ❖ **សុវត្ថិភាព សណ្តាប់ធ្នាប់ ៖**
- ធានាសណ្តាប់ធ្នាប់និង អនាម័យក្នុងបរិវេណជុំវិញ និងជាសុខភាព សម្រាប់សិស្សានុសិស្សទូទៅ ។
- ថែទាំនិងគ្រប់គ្រងសុវត្ថិភាពអគារ (បិទទ្វារបង្អួច ចាក់សោរបន្ទប់ និងទ្វាររបង...) ។
- ពង្រឹងការអនុវត្តន៍ គោលការណ៍ស្តីពីកិច្ចគាំពារកុមារ របស់អង្គការសិល្បៈខ្មែរអមតៈ ។
- ❖ **កម្មវិធីសិល្បៈ ៖**
- ជួយមើលការខុសត្រូវ ក្លឹបសិល្បៈចុងសប្តាហ៍ (ថ្ងៃសៅរ៍ និងអាទិត្យ) ។
- ជួយរៀបចំបន្ទប់រៀន ពេលមានសកម្មភាពសិល្បៈផ្សេងៗ (ដូចជា ការបញ្ចាំងភាពយន្តឯកសារបាបកថាសិល្បៈ និងវគ្គបណ្តុះបណ្តាលនានា) ។
- ទទួលចុះឈ្មោះសិស្សានុសិស្ស ដែលមកចូលរួមកម្មវិធីផ្សេងៗ ។
- ជួយការងារផ្សេងៗ តាមតម្រូវការចាំបាច់ ពេលមានការរៀបចំសម្តែងសិល្បៈ ។
- ❖ **ភារកិច្ចទូទៅ ៖**
- គ្រប់គ្រងកន្លែងចតយានយន្តរបស់បុគ្គលិក និងភ្ញៀវ ។
- ធ្វើបដិសណ្ឋារកិច្ច និងមើលការខុសត្រូវលើភ្ញៀវដែលមកទំនាក់ទំនងការងារ ។
- គ្រប់គ្រងការចុះឈ្មោះភ្ញៀវ ក្នុងសៀវភៅបញ្ជីភ្ញៀវចេញចូល ។
- ជួយរត់សំបុត្រ និងផ្ញើឯកសារផ្សេងៗ តាមតម្រូវការជាក់ស្តែង ។
- ជំនួយការិយាល័យ និងជួយកិច្ចការផ្សេងៗតាមសំណើរបស់អ្នកគ្រប់គ្រង ។

## ផ្នែក ង៖ ជំនាញ និងបទពិសោធន៍ដែលត្រូវការ

- មានបទពិសោធន៍ផ្នែកជំនួយការ និងការងាររដ្ឋបាលទូទៅ ។
- មានបទពិសោធន៍ផ្នែកបដិសណ្ឋារកិច្ចទូទៅ និងប្រកាន់ឥរិយាបទត្រឹមត្រូវជាមួយអនីតិជន ។
- អាននិងសរសេរភាសាខ្មែរបានល្អ, បើអាចទំនាក់ទំនងជាភាសាអង់គ្លេសបាន ជាការប្រសើរ ។
- មានភាពស្មោះត្រង់ រួសរាយរាក់ទាក់ និង យកចិត្តទុកដាក់ក្នុងការងារ ។
- គោរពពេលវេលា និងចេះផ្តល់ដំណឹងត្រឹមត្រូវ ព្រមទាំងមានអធ្យាស្រ័យល្អ ។
- មានក្រមសីលធម៌ល្អប្រសើរ និងចេះគោរពសិទ្ធិកុមារ និងសិស្សានុសិស្ស ។
- ស្រឡាញ់គោរពនិងផ្តល់តម្លៃដល់សិល្បៈវប្បធម៌ ជាអាទិភាព ។

## ផ្នែក ចៈ ប្រាក់បៀវត្ស នឹងអត្ថប្រយោជន៍

| | |
|---|---|
| ប្រាក់ខែចាប់ផ្តើម ៖ | ចន្លោះពី ១៥០ដុល្លា ដល់២០០ដុល្លា/ខែ |
| រយៈពេលសាកល្បងការងារ ៖ | ៣ ខែ |
| ច្បាប់ឈប់សម្រាកប្រចាំឆ្នាំ ៖ | ១៨ ថ្ងៃក្នុងមួយឆ្នាំ |
| ពេលម៉ោងធ្វើការ ៖ | ធ្វើការ៥ថ្ងៃក្នុង១សប្តាហ៍ (តម្រូវឲ្យធ្វើការថ្ងៃសៅរ៍ និង អាទិត្យ) ម៉ោងធ្វើការធម្មតាៈ ព្រឹកម៉ោង ៨.០០ - ១២.០០ និងម៉ោង ២.០០ - ៥.៣០ល្ងាច (ពេលខ្លះតម្រូវឲ្យធ្វើការលើសម៉ោង បើមានកម្មវិធីចាំបាច់) |

## ផ្នែក ឆៈ បែបបទនៃការដាក់ពាក្យ

ដើម្បីដាក់ពាក្យ សូមភ្ជាប់ប្រវត្តិរូបសង្ខេបមានបិទរូបថត និងលិខិតចំណាប់អារម្មណ៍ ផ្ញើទៅកាន់ អង្គការ សិល្បៈខ្មែរអមតៈ តាមរយៈអ៊ីម៉ែល info@cambodianlivingarts.org

ឬផ្ញើទៅ **អង្គការសិល្បៈខ្មែរអមតៈ**

ផ្ទះលេខ 128G9 ផ្លូវសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។
ទូរសព្ទ ០២៣ ៩៨៦ ០៣២

*ឈប់ទទួលពាក្យ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩ ។*

**ចំណាំៈ បេក្ខជនដែលត្រូវបានជ្រើសរើស នឹងតម្រូវឲ្យមានលិខិតពីអាជ្ញាធរមូលដ្ឋានបញ្ជាក់ថាពុំធ្លាប់ជាប់ចោទពីបទរំលោភលើកុមារ ឬអនីតិជន ។**